# សហជីពអន្តរជាតិដើម្បីកម្មករចំណីអាហារនិងពាណិជ្ជកម្មរួបរួម (UFCW) អំពាវនាវដល់ក្រសួងកសិកម្មសហរដ្ឋអាមេរិច (USDA) និងសេតវិមាន ឲ្យការពារកម្មករវេចខ្ចប់សាច់និងការផ្គត់ផ្គង់ស្បៀងរបស់សហរដ្ឋអាមេរិច

ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០

កាលពីសប្ដាហ៍មុន សហជីពអន្តរជាតិដើម្បីកម្មករចំណីអាហារនិងពាណិជ្ជកម្មរួបរួម (UFCW) បានផ្ញើ លិខិតមួយទៅក្រសួងកសិកម្មរបស់សហរដ្ឋអាមេរិច (USDA) ដោយជំរុញឲ្យរដ្ឋមន្ត្រី សូនី ផឺឌូ ចាត់វិធានការជាបន្ទាន់មួយចំនួន ដើម្បីការពារកម្មករវេចខ្ចប់សាច់និងកែច្នៃចំណីអាហារ និងការផ្គត់ផ្គត់ស្បៀងរបស់ប្រទេសយើង ក្នុងអំឡុងពេលនៃការផ្ទុះជំងឺកូវីដ-១៩នេះ ដោយរួមមានទាំង ការធ្វើតេស្តនិងការទទួលបានសម្ភារៈការពារខ្លួនផង។ UFCW ក៏បានផ្ញើ លិខិតមួយទៅកាន់អនុប្រធានាធិបតី ភែន ដែលបានដឹកនាំក្រុមការងារសេតវិមានប្រឆាំងវិរុសក្លូរ៉ូណា ដោយជំរុញឲ្យគាត់ផ្ដល់អាទិភាពដើម្បីឲ្យមានវិធានការដូចគ្នា សម្រាប់កម្មករទាំងនេះ។ UFCW តំណាងឲ្យកម្មករវេចខ្ចប់សាច់និងកែច្នៃចំណីអាហារ ជាង ២៥០.០០០ នាក់ នៅទូទាំងប្រទេស។

នៅក្នុងលិខិតផ្ញើទៅ រដ្ឋមន្ត្រីក្រសួងកសិកម្មរបស់សហរដ្ឋអាមេរិច លោក ផឺឌូ និង អនុប្រធានាធិបតី ភែន, UFCW លើកឡើងនូវជំហានជាបន្ទាន់ចំនួន៥ ដើម្បីការពារកម្មករវេចខ្ចប់សាច់និងកែច្នៃចំណីអាហារ ដូចខាងក្រោម៖

- **ផ្ដល់អាទិភាពដល់កម្មករសំខាន់ចាំបាច់ ក្នុងការទទួលបានការធ្វើតេស្ត៖** ដើម្បីជានាសុខភាពនិងសុវត្ថិភាពរបស់កម្មករ និងដើម្បីការពារការផ្គត់ផ្គង់ស្បៀង កម្មករសំខាន់ចាំបាច់ ដូចជាអ្នកធ្វើការក្នុងផ្នែកវេចខ្ចប់សាច់និងកែច្នៃអាហារ ត្រូវតែផ្ដល់អាទិភាពក្នុងការធ្វើតេស្ត។
- **ការទទួលបានសម្ភារៈការពារខ្លួនជាបន្ទាន់៖** ទោះបីជាការរក្សាគម្លាតសង្គមនិងរាងកាយ មានភាពសំខាន់ចាំបាច់ ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏កម្មករនៅតែត្រូវការទទួលបានសម្ភារៈការពារខ្លួន ដូចជា ម៉ាសមុខនិងស្រោមដៃ។ តថភាពជាក់ស្ដែង គឺថា សមាជិករបស់យើងភាគច្រើន ខ្វះសម្ភារៈការពារខ្លួនសំខាន់ៗ ដែលចាំបាច់សម្រាប់បំពេញការងាររបស់ខ្លួន និងដើម្បីកាត់បន្ថយហានិភ័យនៃការប្រឈមមុខ។ វាជាការសំខាន់ចាំបាច់ណាស់ ដែលក្រសួងកសិកម្មរបស់សហរដ្ឋអាមេរិច រួមជាមួយនិងក្រុមការងាររបស់សេតវិមាន ផ្ដល់អាទិភាពដល់កម្មករវេចខ្ចប់សាច់និងកែច្នៃចំណីអាហារ ក្នុងការទទួលបានសម្ភារៈការពារខ្លួន ដើម្បីជានាសុខភាពនិងសុវត្ថិភាពរបស់កម្មករទាំងនេះ និងដើម្បីការពារការផ្គត់ផ្គង់ស្បៀងដល់យើងទាំងអស់គ្នា។

- **ការបញ្ឈប់ជាបន្ទាន់អំពីការលើកលែងការអនុវត្តតាមល្បឿនផលិតកម្ម៖** នៅក្នុងរយៈពេល២សប្តាហ៍ដំបូងក្នុងខែនេះ សេវាកម្មអធិការកិច្ចចំណីអាហារនិងសុវត្ថិភាព [បានអនុម័ត] ការលើកលែងផ្នែកនិយ័តកម្មចំនួន ១១ សម្រាប់រោងចក្រផលិតកម្មសត្វបក្សី ដើម្បីបង្កើនល្បឿនផលិតកម្មឲ្យដល់កម្រិតអតិបរមា។ ជំនួសឲ្យការការពារការផ្គត់ផ្គង់ចំណីអាហារនិងកម្មកររបស់យើង ការលើកលែងទាំងនេះ ធានាថាកម្មករកាន់តែមានភាពកកកុញ នៅតាមខ្សែបន្ទាត់ផលិតកម្មវេចខ្ចប់សាច់ និងកម្មករកាន់តែច្រើន ត្រូវស្ថិតនៅក្នុងហានិភ័យនៃការឆ្លងមេរោគនិងធ្វើឲ្យមេរោគសាយភាយ។ វាជាការសំខាន់ណាស់ដែលក្រសួងកសិកម្មសហរដ្ឋអាមេរិចត្រូវបញ្ឈប់ជាបន្ទាន់ ក្នុងការផ្តល់ការលើកលែងថ្មីៗណាមួយ និងត្រូវព្យួរការលើកលែងដែលមានស្រាប់ទាំងអស់ ដែលអនុញ្ញាតិឲ្យរោងចក្រ ប្រតិបត្តិក្នុងល្បឿនកាន់តែលឿននេះ។
- **ដាក់កំហិតដាច់ខាតអំពីការរក្សាគម្លាតសង្គមនៅកន្លែងដែលអាចធ្វើបាន៖** ដើម្បីការពារកម្មករនិងទប់ស្កាត់ការរីករាយដាលនៃជំងឺ ប្រកបដោយការទទួលខុសត្រូវនោះ ក្រុមហ៊ុននានា ត្រូវតែពង្រឹងនិងអនុវត្តគម្លាតសង្គមនិងរាងកាយចំនួន៦ហ្វីត (ប្រហែល ២ ម៉ែត្រ) ឲ្យបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាន ទោះបីជាវាធ្វើឲ្យផលិតកម្មមានការថយយឺតក៏ដោយ។ នៅកន្លែងដែលមិនអាចរក្សាគម្លាតបាន ក្រុមហ៊ុនគួរប្រើប្រាស់របាំងកញ្ចក់ផ្លាស្ទិក ដើម្បីបំបែកនិងការពារកម្មករ និង/ឬ ធានាថារាល់កម្មករទាំងអស់ ទទួលបានការផ្តល់ម៉ាសមុខ ដែលអាចប្រើប្រកបដោយប្រសិទ្ធភាពនៅក្រោមលក្ខខណ្ឌធ្ងន់ធ្ងរទាំងនេះ។
- **ដាក់កម្មករដែលបញ្ចេញរោគសញ្ញាឬធ្វើតេស្តវិជ្ជមាននៃជំងឺកូវីដ-១៩ឲ្យនៅដាច់ដោយឡែក៖** ដោយសារតែការផ្ទុះដ៏ធំបំផុតរហូតមកដល់ពេលនេះ នៅរោងចក្រស្មីតហ្វៀល ហ្វូត នៅក្នុងតំបន់ ស៊ីអ៊ូក ហ្វល នៃរដ្ឋដាកូតាខាងត្បូង វាជាការសំខាន់ណាស់ដែលត្រូវកំណត់រកឲ្យឃើញ និងដាក់ឲ្យដាច់ដោយឡែកចំពោះកម្មករណាដែលបានធ្វើតេស្តវិជ្ជមាន ឬដែលបង្ហាញរោគសញ្ញាជំងឺកូវីដ-១៩។ កម្មករទាំងនេះ គួរត្រូវបានអនុញ្ញាតិឲ្យនៅដាច់ដោយឡែកនៅផ្ទះ ដោយមានប្រាក់កម្រៃ ដូចអនុសាសន៍ដែលបានបង្កើតឡើងដោយមជ្ឈមណ្ឌលសម្រាប់ការត្រួតត្រានិងការទប់ស្កាត់ជំងឺ។

នៅក្នុងការអំពាវនាវក្នុងសន្និសីទសារព័ត៌មានមួយកាលពីសប្តាហ៍មុន UFCW បានបង្ហាញនូវបច្ចុប្បន្នភាពស្តីពីផលប៉ះពាល់ធ្ងន់ធ្ងរនិងដល់ជីវិត ដោយសារតែវីរុសកូវីដ-១៩នេះ។ ផ្អែកតាមការប៉ាន់ប្រមាណផ្ទៃក្នុងរបស់ UFCW នាពេលថ្មីៗនេះ មានកម្មករវេចខ្ចប់សាច់និងកែច្នៃចំណីអាហារចំនួន២០នាក់ បានស្លាប់។ បន្ថែមពីលើនេះ យ៉ាងហោចណាស់កម្មករវេចខ្ចប់សាច់ចំនួន ៥,០០០នាក់ និងកម្មករកែច្នៃចំណីអាហារចំនួន ១,៥០០នាក់ បានទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីវីរុសនេះ។ ការប៉ាន់ប្រមាណទៅលើកម្មករវេចខ្ចប់សាច់និងកែច្នៃចំណីអាហារដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់នេះ រួមមានទាំងបុគ្គលដែលបានធ្វើតេស្តវិជ្ជមានរកឃើញជំងឺកូវីដ-១៩ បានខកខានទៅធ្វើការ ដោយសារតែការដាក់ខ្លួនឲ្យនៅដាច់ដោយឡែកផងនោះ កំពុងរង់ចាំលទ្ធផលធ្វើតេស្ត ឬត្រូវបានសម្រាកនៅមន្ទីរពេទ្យ និង/ឬ កំពុងមានរោគសញ្ញា។

ការប៉ាន់ប្រមាណថ្មីក៏បានបង្ហាញដែរថា រោងចក្រចំនួន២២ ទាំងមានសហជីពនិងគ្មានសហជីព បានបិទដំណើរការនៅពេលណាមួយក្នុងរយៈពេលពីរខែចុងក្រោយនេះ។ ការបិទដំណើរការនេះ បានប៉ះពាល់ដល់កម្មករជាង ៣៥,០០០ និងកាត់បន្ថយសមត្ថភាពពិឃាដយកសាច់ជ្រូកចំនួន២៥% និងសាច់គោចំនួន១០%។

ក្នុងអំឡុងពេលអំពាវនាវក្នុងសន្និសីទសារព័ត៌មាននោះ ការគំរាមកំហែងទៅលើកម្លាំងការងារផ្នែកវេចខ្ចប់ត្រូវបានរំលេចឡើងដោយស្ថានភាពផ្ទាល់ខ្លួនជាក់ស្តែងរបស់កម្មករប្រាំនាក់ ដែលបានពិភាក្សាអំពីហានិភ័យសំខាន់ចម្បងៗ ដែលពួកគេនិងសហការីរបស់ពួកគេ កំពុងប្រឈមរាល់ថ្ងៃ នៅក្នុងរោងចក្រវេចខ្ចប់សាច់ដ៏ធំជាងគេបំផុតមួយចំនួននៅក្នុងប្រទេស។ ក្នុងចំណោមហានិភ័យជាក់លាក់នានាដែលបានរំលេចឡើងដោយកម្មករទាំងនេះ គឺការប្រឈមដែលកើតឡើងដោយសារតែកង្វះសម្ភារៈការពារខ្លួន ក៏ដូចជា ការបង្កើនល្បឿនផលិតកម្ម ដែលធ្វើឲ្យការរក្សាគម្លាតសង្គម មិនអាចធ្វើទៅបាន។

"កម្មករវេចខ្ចប់សាច់និងកែច្នៃចំណីអាហាររបស់សហរដ្ឋអាមេរិច ស្ថិតនៅក្នុងគ្រោះថ្នាក់ខ្លាំងក្រៃលែង ហើយការផ្គត់ផ្គង់ស្បៀងរបស់ប្រទេសយើង ប្រឈមមុខនឹងការគំរាមកំហែងដោយផ្ទាល់ពីការផ្ទុះវីរុសកូរ៉ូណា។ ប្រសិនបើកម្មករនៅក្នុងរោងចក្រទាំងនេះ មានភាពសំខាន់ចាំបាច់ ដូចដែលមេដឹកនាំជាប់ឆ្នោតរបស់យើងបាននិយាយមែននោះ គឺវាដល់ពេលដែលអ្នកដឹកនាំជាប់ឆ្នោតរបស់យើង ផ្តល់ដល់ពួកគេ នូវការការពារសំខាន់ចាំបាច់ដែលពួកគេត្រូវការ។ សូមកុំមានការភាន់ច្រឡំ ប្រសិនបើគ្មានស្តង់ដាសុវត្ថិភាពថ្នាក់ជាតិ ក្នុងការការពារកម្មករទាំងនោះ ពីវីរុសកូរ៉ូណាទេ វានឹងមានការបាត់បង់ជីវិតកាន់តែច្រើន កម្មករកាន់តែច្រើននឹងត្រូវប្រឈមនឹងគ្រោះថ្នាក់ ហើយការផ្គត់ផ្គង់ស្បៀងរបស់យើង ក៏នឹងប្រឈមគ្រោះថ្នាក់ដែរ។" នេះជាការលើកឡើងរបស់ប្រធាន UFCW អន្តរជាតិ ម៉ាក ភែរ៉ូន។

"នៅទូទាំងប្រទេសនេះ យើងកំពុងតែឃើញផលប៉ះពាល់ នៅពេលដែលរដ្ឋាភិបាល ខកខានមិនបានចាត់វិធានការ ក្នុងការការពារកម្មករសំខាន់ចាំបាច់ទាំងនេះ។ រដ្ឋាភិបាល ត្រូវការផ្តល់ការធ្វើតេស្ត និងសម្ភារៈការពារ ព្រមទាំងចេញការណែនាំអំពីសុវត្ថិភាពឲ្យបានច្បាស់លាស់និងដោយផ្ទាល់ ដែលក្រុមហ៊ុនអាចអនុវត្តបាននិងត្រូវតែអនុវត្ត។ នេះមិនមែនគ្រាន់តែអំពី ថាតើយើងនឹងមានសាច់គោ សាច់មាន់ និងសាច់ជ្រូក ដើម្បីចិញ្ចឹមគ្រួសាររបស់យើងឬមិនមាននោះទេ។ សម្រាប់កម្មករទាំងនេះ វាគឺជាបញ្ហាស្លាប់រស់" លោក ភែរ៉ូន បន្ថែម។

អ្នកអាចអានលិខិតក្រសួងកសិកម្មសហរដ្ឋអាមេរិច នៅទីនេះ និងលិខិតទៅកាន់អនុប្រធានាធិបតី ភែន នៅទីនេះ។